# សេចក្តីសង្កេតសន្និដ្ឋាន និងអនុសាសន៍ របស់គណៈកម្មាធិការ ស៊ី-ដ ក្នុងរបាយការណ៍ជាតិទី ៤-៥

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

1



# សេចក្តីសង្ខេបសន្និដ្ឋាន និងអនុសាសន៍

គណៈកម្មាធិការស្វាគមន៍ចំពោះរដ្ឋភាគីដែលបានចុះហត្ថលេខា និង

ផ្តល់សច្ចាប័នលើសន្ធិសញ្ញា

- ចុះហត្ថលេខាទទួលស្គាល់អនុសញ្ញា CEDAW ថ្ងៃទី១៧ ខែតុលាឆ្នាំ ១៩៨០។
- ផ្តល់សច្ចាបន័លើអនុសញ្ញា CEDAW នៅថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៩២។
- ពិធីសារតាមជម្រើស នៃអនុសញ្ញា CEDAW នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០១០។

# គ្រប់ក្រសួង ស្ថាប័ន យុត្តិធម៌

- គួរតែបញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រីដែលគ្របដណ្តប់លើការរើសអើងដោយផ្ទាល់ ដោយប្រយោល។
- បង្កើតការយល់ដឹងអំពីអនុសញ្ញា និងពិធីសារតាមជម្រើសចំណោមចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ។
- បន្តបញ្ចូលការបណ្តុះបណ្តាលស្តីពីអនុសញ្ញាក្នុងកម្មវិធីអប់រំពាក់ព័ន្ធសម្រាប់មន្ត្រីរាជការ មន្ត្រីតុលាការ និងអ្នកដែលបានប្រើប្រាស់ក្នុងប្រព័ន្ធអប់រំ។

# យុត្តិធម៌ អង្គភាពប្រឆាំងអំពើពុករលួយ

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

- បង្កើតគម្រោងជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយ ធានាថាស្ត្រីទទួលបានសេវាពីតុលាការ និងសាលាជម្រះក្តី។
- ផ្តល់ថវិកាគ្រប់គ្រាន់ដល់គណៈមេធាវី អង្គការរបស់ស្ត្រី។
- បន្តស៊ើបអង្កេត និងចោទប្រកាន់លើករណីពុករលួយក្នុងតុលាការផ្តន្ទាទោសអ្នកប្រព្រឹត្ត។

# យុត្តិធម៌

- ផ្តល់សំណងដល់ជនរងគ្រោះដោយអំពើហិង្សាផ្តោតលើយេនឌ័រ អំពើហិង្សា ផ្លូវភេទ ប្រព្រឹត្តក្នុងរបបខ្មែរក្រហម។
- ផ្តល់សំណងជួសជុលគ្រប់គ្រាន់ ការគាំទ្រផ្លូវចិត្ត និងការគាំទ្រសមស្រប ផ្សេងទៀត។
- បង្កើនការបែងចែកថវិកាសម្រាប់យន្តការជាតិ។
- ការបែងចែកថវិកាត្រូវបានពិនិត្យវាយតម្លៃជាទៀងរាល់ឆ្នាំ និងកែតម្រូវតាម ការចាំបាច់។

# ព័ត៌មាន  វប្បធម៌ និងវិចិត្រសិល្បៈ

United Nations Entity for Gender Equality and the Empowerment of Women

- បញ្ចូលយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈ ទី៤ ដែលមានគោលបំណងកែសម្រួល ឬលុបបំបាត់ផ្នត់គំនិតបិតាធិបតេយ្យ ទស្សនៈតាមទម្លាប់រើសអើង រាប់បញ្ចូលទាំងផ្នត់គំនិត និងទស្សនៈតាមទម្លាប់ផ្អែកលើច្បាប់ស្រី។
- ផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈ។
- ដោះស្រាយផ្នត់គំនិត និងទស្សនៈតាមទម្លាប់ដែលរើសអើង ដោយសហការជាមួយសង្គមស៊ីវិល អ្នកដឹកនាំសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយ។

# ព័ត៌មាន_វប្បធម៌ និងវិចិត្រសិល្បៈ (ត)

United Nations Entity for Gender Equality and the Empowerment of Women

- សិក្សាពិនិត្យលើការប្រើប្រាស់បច្ចេកវិជ្ជា សារគមនាគមន៍ព័ត៌មាន ផ្សព្វផ្សាយព័ត៌មានអំពីសិទ្ធិស្ត្រី និងសមភាពយេនឌ័រ។
- បង្កើតយន្តការពិនិត្យតាមដាន វាយតម្លៃ ក្នុងគោលបំណង វាយតម្លៃវឌ្ឍនភាពក្នុងការលុបបំបាត់ផ្នត់គំនិតយេនឌ័រ ដែលមានស្រាប់។

# យុត្តិធម៌ - តុលាការ

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

- បណ្ដុះបណ្ដាលមន្ត្រីតុលាការ មន្ត្រីអនុវត្តច្បាប់អំពីការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីធានាថាករណីអំពើហិង្សាលើស្ត្រី រាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារនិងអំពើហិង្សាផ្លូវភេទ ត្រូវបានចោទប្រកាន់ប្រកបដោយប្រសិទ្ធភាព មិនត្រូវបានបង្វែទៅជាការសម្រុះសម្រួលជាលក្ខណៈប្រព័ន្ធ។
- លើកទឹកចិត្តស្ត្រីឲ្យដាក់បណ្ដឹងជាផ្លូវការលើអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ។

# យុត្តិធម៌ - តុលាការ (ត)

- បណ្តោះបណ្តាលមន្ត្រីតុលាការ មន្ត្រីអនុវត្តច្បាប់អំពីការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដើម្បីធានាថាករណីអំពើហិង្សាលើស្ត្រី រាប់បញ្ចូលទាំងអំពើហិង្សាក្នុងគ្រួសារនិងអំពើហិង្សាផ្លូវភេទ ត្រូវបានចោទប្រកាន់ប្រកបដោយប្រសិទ្ធភាព មិនត្រូវបានបង្វែទៅជាការសម្រុះសម្រួលជាលក្ខណ:ប្រព័ន្ធ។

- លើកទឹកចិត្តស្ត្រីឲ្យដាក់បណ្តឹងជាផ្លូវការលើអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ។

- លើកកម្ពស់ការយល់ដឹងជាសាធារណ:អំពីអំពើហិង្សាលើស្ត្រីគ្រប់រូបភាព។

# យុត្តិធម៌ - តុលាការ(ត)

United Nations Entity for Gender Equality and the Empowerment of Women

- ផ្តល់ព័ត៌មានអំពីចំនួនដីកាការពារដែលត្រូវបានចេញដោយតុលាការក្នុងអំឡុងពេលរាយការណ៍។
- ចំនួនទីជម្រកដែលមានសម្រាប់ស្ត្រីដែលជាជនរងគ្រោះដោយ អំពើហិង្សា នៅក្នុងរបាយការណ៍តាមកាលកំណត់លើកក្រោយ។

# សុខាភិបាល

- លើកកម្ពស់ការយល់ដឹងក្នុងចំណោមគ្រូពេទ្យអំពីរបៀបគ្រប់គ្រងករណីអំពើហិង្សាលើស្ត្រី ។
- លើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល លើកលែងការបង់ថ្លៃសម្រាប់រាល់ការពិនិត្យកោសលវិច័យរបស់ជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈនិងការបំពានផ្លូវភេទ។
- ធានាថា មធ្យោបាយរំលូតកូនទំនើបដែលមានសុវត្ថិភាពផ្នែកវេជ្ជសាស្ត្រអាចរកបានប្រើប្រាស់ស្របតាមអនុសាសន៍ទូទៅលេខ២៤ (ឆ្នាំ២០០៤) ។

# សុខាភិបាល (ត)

- ផ្តល់ការព្យាបាលដោយផ្តល់ថ្នាំប្រឆាំងនឹងមេរោគអេដស៍ដល់ស្ត្រី និងបុរសដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ រាប់បញ្ចូលទាំងស្ត្រីរកស៊ីផ្លូវភេទ និងស្ត្រីមានផ្ទៃពោះ។

- បង្កើនការផ្តល់ព័ត៌មាន និងសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដល់ស្ត្រី មធ្យោបាយពន្យារកំណើតទំនើប ជាពិសេសដល់ស្ត្រីដែលរស់នៅតំបន់ជនបទ។

# សុខាភិបាល (ត)

United Nations Entity for Gender Equality and the Empowerment of Women

- ពង្រឹងការអនុវត្តកម្មវិធី និងគោលនយោបាយដែលមានគោលបំណង ផ្តល់សេវាថែទាំសុខភាពដែលមានតម្លៃសមស្របដល់ស្ត្រី ជាពិសេសស្ត្រីក្រីក្រ ស្ត្រីពិការ និងស្ត្រីចាស់ជរា ។
- យកចិត្តទុកដាក់ជាពិសេសចំពោះតម្រូវការផ្នែកសុខភាពរបស់ស្ត្រីពិការ ដោយធានាថា ស្ត្រីទាំងនេះទទួលបានការថែទាំមុនសម្រាល និងសេវាសុខភាពបន្តពូជ។
- ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការរើសអើងលើស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ ។

# មហាផ្ទៃ- ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

United Nations Entity for Gender Equality and the Empowerment of Women

- បង្កើនការផ្សព្វផ្សាយព័ត៌មានអំពីទេសន្តប្រវេសន៍ដើម្បីការងារនិងផ្តល់ព័ត៌មានអំពីក្រុមហ៊ុនបោកប្រាស់ជ្រើសរើសពលករ ពលការិនី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។
- អ្នកជួញដូរមនុស្ស និងអ្នកដទៃទៀតដែលទទួលខុសត្រូវចំពោះអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងក្មេងស្រី ត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសប្រកបដោយប្រសិទ្ធភាព ។
- ពង្រឹងសហប្រតិបត្តិការទ្វេភាគី ពហុភាគី ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស សម្រាប់ការងារបម្រើតាមផ្ទះ និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

# មហាផ្ទៃ- ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ត)

United Nations Entity for Gender Equality and the Empowerment of Women

- បញ្ចូលទិន្នន័យអំពីពលករ ពលការិនីទេសន្តប្រវេសន៍បម្រើការងារតាមផ្ទះ ដែលជាជនរងគ្រោះដោយអំពើជួញដូរ ព័ត៌មានអំពីយន្តការជាតិសម្រាប់ការបញ្ជូន ជនរងគ្រោះដោយអំពើជួញដូរត្រូវបានកំណត់អត្តសញ្ញាណសមស្រប ត្រូវបានគាំទ្រគ្រប់គ្រាន់ និងការពារពីការជួញដូរ។

# មហាផ្ទៃ

United Nations Entity for Gender Equality and the Empowerment of Women

- ចោទប្រកាន់ករណីបំពានផ្លូវភេទ ដោយមន្ត្រីអនុវត្តច្បាប់ដែលបានប្រព្រឹត្តលើស្ត្រីរកស៊ីផ្លូវភេទ ជនល្មើសត្រូវបានផ្តន្ទាទោសដោយទណ្ឌកម្មសមស្រប។
- បង្កើតគោលនយោបាយដ៏គ្រប់ជ្រុងជ្រោយដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលទាក់ទងនឹងតម្រូវការពេស្យាចារ និងពិចារណាលើការដាក់ទណ្ឌកម្មលើអ្នកទិញសេវាផ្លូវភេទ។
- ពិចារណាលើការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ១៩៥១ ស្តីពីស្ថានភាពរបស់ជនដែលគ្មានរដ្ឋ និងអនុសញ្ញាឆ្នាំ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានរដ្ឋ។
- ជួយសម្រួលដល់ការចុះបញ្ជីកំណើតកូនរបស់ស្ត្រីវៀតណាម និងការទទួលបានសញ្ជាតិ។
- ពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

# យុត្តិធម៌ - ការបរទេស

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

- ធានាថា ផែនការនារីរតនៈទី៤ ផ្តល់នូវយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព រាប់បញ្ចូលទាំងវិធានការពិសេសបណ្តោះអាសន្ន ដែលមានគោលបំណង បង្កើនតំណាងរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច ក្នុងកិច្ចការនយោបាយ តុលាការ ការទូត និងការបរទេស។



# អប់រំ យុវជន និងកីឡា

- បង្កើនការទទួលបានការអប់រំសម្រាប់កុមារី ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធ បង្កើននៅក្នុងសាលាមធ្យមសិក្សា ពិសេសនៅក្នុងឃុំ។

- បង្កើតវិធានការ ធានាឲ្យបាននូវការរក្សាស្ត្រី និងកុមារីនៅក្នុងសាលា នៅពេលឆ្លងពីបឋមសិក្សាទៅមធ្យមសិក្សា និងកម្រិតឧត្តមសិក្សា។

- បង្កើនការអប់រំដែលសមស្របតាមអាយុអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជនៅតាមសាលារៀនអំពីទំនាក់ទំនងយេនឌ័រ និងការប្រព្រឹត្តផ្លូវភេទដែលមានការទទួលខុសត្រូវដើម្បីទប់ស្កាត់ការមានគភ៌វ័យក្មេង។

- លើកកម្ពស់គុណភាពនៃការអប់រំ តាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន និងធានាថា គ្រូបង្រៀនទទួលបានប្រាក់បំណាច់គ្រប់គ្រាន់។

# ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

UN WOMEN
United Nations Entity for Gender Equality
and the Empowerment of Women

- លុបបំបាត់ការបែងចែកមុខងារ  និងបញ្ចប់គម្លាតប្រាក់ឈ្នួល។
- ចាត់វិធានការដើម្បីធានាថា ច្បាប់ការងារត្រូវបានអនុវត្ត។
- បង្កើនចំនួននៃអធិការការងារដែលមានសមត្ថភាពជួយដល់ការពិនិត្យតាមដានលក្ខខណ្ឌ ការងាររបស់ស្ត្រីក្នុងឧស្សាហកម្មកាត់ដេរ និងវិស័យដែលមានប្រាក់ឈ្នួលទាប។
- ពិចារណាលើការងារសមរម្យសម្រាប់កម្មករ  កម្មការិនីបម្រើការងារតាមផ្ទះ។

# អភិវឌ្ឍន៍ជនបទ_កសិកម្ម_ការងារ_និងបរិស្ថាន

UN WOMEN
United Nations Entity for Gender Equality and the Empowerment of Women

- ជួយសម្រួលឲ្យស្ត្រីជនបទទទួលសេវាមូលដ្ឋាន បង្គន់ទឹកពិសាសុវត្ថិភាព ការអប់រំ ការងារ សេវាសុខាភិបាល ឥណទាន និងប្រាក់កម្ចី។

- បញ្ចូលបច្ចេកវិជ្ជាទំនាក់ទំនងព័ត៌មាន ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីសម្រាប់ស្ត្រីដែលរស់នៅតំបន់ជនបទ។

- បង្កើតសូចនាករដែលឆ្លុះបញ្ចាំងបានល្អប្រសើរពីការផ្លាស់ប្តូរតំបន់ និងការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម ក្នុងការលើកកម្ពស់កម្មវិធីសុខភាពអប់រំ និងការងារសម្រាប់ស្ត្រីជនបទ។

- បន្តធានាថា ស្ត្រីចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេច ទាំងក្នុងនយោបាយ និងកម្មវិធីទប់ស្កាត់ និងគ្រប់គ្រងគ្រោះមហន្តរាយ និងកម្មវិធីទាក់ទងនឹងការបន្សុាំ និងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

# មហាផ្ទៃ- រៀបចំដែនដី

United Nations Entity for Gender Equality and the Empowerment of Women

- ធ្វើឲ្យប្រសើរឡើងនូវការទទួលបានដីធ្លី និងសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លីសម្រាប់ស្ត្រី សំណាងគ្រប់គ្រាន់ត្រូវបានផ្តល់ ។
- ការបណ្តេញចេញដោយបង្ខំ មិនមែនហេតុការណ៍ដែលមានអព្យាក្រិតភាពយេនឌ័រ ចាត់វិធានការបន្ទាន់ដើម្បីការពារស្ត្រី និងកុមារពីការបណ្តេញចេញបន្ថែមទៀត។
- ស៊ើបអង្កេតជាបន្ទាន់ ធ្វើការចោទប្រកាន់លើករណីបំភិតបំភ័យ និងបៀតបៀន ដែលត្រូវបានប្រព្រឹត្តដោយមន្ត្រីអនុវត្តច្បាប់លើស្ត្រីជាអ្នកការពារសិទ្ធិមនុស្ស ដែលតស៊ូមតិដើម្បីសិទ្ធិដីធ្លី។

# មុខងារសាធារណៈ និង សង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិម្បទា

United Nations Entity for Gender Equality and the Empowerment of Women

- ប្រមូល និងវិភាគទិន្នន័យដោយបែងចែកតាមអាយុ និងភេទ សម្រាប់ធ្វើគោលនយោបាយ និងអនុវត្តវិធីសាស្រ្តរយៈពេលយូរសម្រាប់ដោះស្រាយការរើសអើងលើស្រ្តីចាស់ជរា



# យុត្តិធម៌ _មហាផ្ទៃ

United Nations Entity for Gender Equality
and the Empowerment of Women

- រដ្ឋភាគីធ្វើនិរាករណ៍លើមាត្រា៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលមានលក្ខណៈរើសអើង និងរិតត្បឹតដោយមិនសមស្របនូវសិទ្ធិរបស់ស្ត្រី ក្នុងការរៀបការម្តងទៀត ពីព្រោះបិតុភាពអាចត្រូវបានបង្កើតឡើងយ៉ាងងាយស្រួល ដោយមធ្យោបាយដែលមិនសូវរិតត្បឹតក្នុងវិស័យវេជ្ជសាស្ត្រ។
- រដ្ឋភាគីចាត់វិធានការនានាដើម្បីសម្រួលដល់ការរៀបការតាមរយៈច្បាប់ប្រពៃណីមានលក្ខណៈផ្លូវការ ការចុះលិខិតបញ្ជាក់អាពាហ៍ពិពាហ៍មានតម្លៃសមរម្យ និងគ្មានបន្ទុកខ្លាំង។
- រដ្ឋភាគីបញ្ចូលទស្សនៈយេនឌ័រ ក្នុងរាល់កិច្ចប្រឹងប្រែង ដែលមានគោលបំណងក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្ស និងក្របខណ្ឌអភិវឌ្ឍន៍ថ្មីត្រឹមឆ្នាំ២០១៥។

# សូមអរគុណ

UN WOMEN
United Nations Entity for Gender Equality
and the Empowerment of Women



